**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ..០០២...សស.កស.ក /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី...១២... ខែ..កុម្ភៈ ឆ្នាំ២០១០

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសមាហរណកម្មមន្ត្រីរាជការនៃរចនាសម្ព័ន្ធ សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោជាតិ
- យោងសេចក្តីណែនាំលេខ ០០៥ សណន ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងមន្ត្រីរាជការដែលមានបច្ចុប្បន្ន នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានបង្កើត**ក្រុមការងារ**សមាហរណកម្មមន្ត្រីរាជការនៃរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបច្ចុប្បន្ន ទៅក្នុងរចនាសម្ព័ន្ធថ្មី ស្របទៅតាមគោលការណ៍ បែបបទ និងនីតិវិធី ដែលបានកំណត់ ។ ក្រុមការងារនេះ មានសមាសភាពមកពីក្រសួង ស្ថាប័ន ដូចខាងក្រោម:

| | |
|---|---|
| ១-តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប | ប្រធាន |
| ២-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | អនុប្រធាន |
| ៣-តំណាងក្រសួងមហាផ្ទៃ | សមាជិកអចិន្ត្រៃយ៍ |
| ៤-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-តំណាងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិក ។ |

ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវបញ្ជូនសមាសភាពក្រុមការងារ មកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីរៀបចំដាក់ជូន គ.ជ.អ.ប ពិនិត្យ និង សម្រេច ។

**ប្រការ ២** : ក្រុមការងារខាងលើ មានតួនាទី ភារកិច្ចដូចខាងក្រោម :

- រៀបចំផ្សព្វផ្សាយដល់រាជធានី ខេត្ត អំពីដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នទៅក្នុងរចនាសម្ព័ន្ធថ្មី តាមការចាំបាច់
- ណែនាំ និងគាំទ្រផ្នែកបច្ចេកទេស ជំនាញ និងសមត្ថភាពដល់រាជធានី ខេត្តក្នុងដំណើរការសមាហរណកម្ម
- ចូលរួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតំលៃទៅលើដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មី របស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បូកសរុបលទ្ធផល និងធ្វើរបាយការណ៍អំពីដំណើរការនៃការធ្វើសមាហរណកម្មមន្ត្រីរាជការនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធថ្មី ជូនលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីរាយការណ៍ជូន គ.ជ.អ.ប
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ។

**ប្រការ ៣** : ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចសម្របសម្រួលយន្តការរវាងក្រុមការងារខាងលើ ជាមួយរាជធានី ខេត្ត នៅក្នុងដំណើរការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងរចនាសម្ព័ន្ធថ្មី ។

ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសម្របសម្រួលរៀបចំសមាសភាពមន្ត្រីដែលពាក់ព័ន្ធសំខាន់ៗជាក់ស្តែងនៅតាមបណ្តាអង្គភាពនានាចំណុះក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជួយគាំទ្រដល់ក្រុមការងារ និងរាជធានី ខេត្ត ក្នុងដំណើរការធ្វើសមាហរណកម្មនេះ ។

**ប្រការ ៤** : ការចំណាយ សោហ៊ុយបេសកកម្ម និងមធ្យោបាយផ្សេងៗ ក្នុងការបំពេញភារកិច្ចរបស់ក្រុមការងារ ជាបន្ទុករបស់លេខាធិការដ្ឋាន គ.ជ.អ.ប ។

**ប្រការ ៥** : លេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាសភាពដូចមានក្នុងប្រការ១ខាងលើ និងអង្គភាពពាក់ព័ន្ធនានាចំណុះទីស្តីការក្រសួងមហាផ្ទៃ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

ស ខេង

**កន្លែងទទួល :**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.អ.ប*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *"ដើម្បីជូនជ្រាប"*
- *ដូចប្រការ ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ - កាលប្បវត្តិ*